**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation
លេខ: ២១៦ MISTI / ២០២០

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រង និងនីតិវិធីចុះបញ្ជីការពារពូជថ្មីនៃដំណាំ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

### ប្រការ១.- គោលបំណង

ប្រកាសនេះ កំណត់អំពីការការពារពូជថ្មីនៃដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ២.- គោលដៅ

ប្រកាសនេះមានគោលដៅផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ និងគ្រប់គ្រងការចុះបញ្ជីការពារពូជថ្មីនៃដំណាំអនុលោមតាមច្បាប់។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

### ប្រការ៣._ វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ ការការពារពូជថ្មីនៃដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៤._ វាក្យស័ព្ទសំខាន់ៗ

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះមាន៖

- **ច្បាប់** សំដៅដល់ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។
- **មន្ត្រីកាន់កាប់បញ្ជី** សំដៅដល់ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។
- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** សំដៅដល់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។
- **សំណុំលិខិតស្នើសុំដំបូង** សំដៅដល់សំណុំលិខិតស្នើសុំដែលបានដាក់ពាក្យសុំ ឬសុំចុះបញ្ជីមុនដំបូងគេ។
- **ពូជ** សំដៅដល់រាល់ប្រភេទពូជដំណាំ ឬក្រុមផ្សេងៗនៃប្រភេទពូជដំណាំណាមួយដែលមានលក្ខណៈដូចគ្នា និងធ្វើឱ្យឃើញប្លែកពីរុក្ខជាតិដទៃទៀតក្នុងប្រភេទពូជដំណាំតែមួយក្នុងលក្ខណៈមួយ ឬច្រើន ហើយដែលលក្ខណៈទាំងនេះនៅតែអាចរក្សាបាន ដើម្បីយកទៅប្រើប្រាស់ធ្វើជាពូជដំណាំបាន ឬការបង្កាត់ដោយសរីរាង្គដទៃទៀត។
- **ពូជថ្មីនៃដំណាំ** សំដៅដល់ពូជដំណាំទាំងឡាយដែលទើបនឹងរកឃើញ និងអភិវឌ្ឍថ្មីៗដោយរុក្ខជម្រើសវិទូ ឬអ្នកបង្កាត់ពូជដំណាំ និងកាន់កាប់ផ្តាច់មុខយ៉ាងទូលំទូលាយក្នុងរយៈពេលមួយជាក់លាក់ដែលកំណត់ដោយច្បាប់នេះ។
- **ពន្ធុ** សំដៅដល់ក្រុមនៃក្រូម៉ូសូម ដែលជាឯកតាបន្តពូជអាចបញ្ជូនព័ត៌មានតំណពូជ ពីជំនាន់មួយទៅជំនាន់មួយក្រោយទៀត ឬពីមេបាទៅកូន។
- **វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ** សំដៅដល់លិខិតបញ្ជាក់សិទ្ធិអ្នកបង្កាត់ពូជដំណាំដែលផ្តល់ជូនរូបវន្តបុគ្គល ឬនីតិបុគ្គលនូវសិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំ ដែលផ្តល់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- **ការបណ្តុះពូជដំណាំ** សំដៅដល់បំណែកពូជដំណាំ ដែលបំណែកពូជដំណាំទាំងនេះអាចធ្វើការដាំដុះសាជាថ្មីវិញដូចជា៖ ការបណ្តុះពីគ្រាប់ពូជឱ្យមានរូបរាងជាកូនដំណាំ ឬក្លាយជាកូនឈើតូចៗ ការបំបៅមែក ការកាត់ផ្សាំដើម មើម ផ្លែ ពន្លក ក្រពុំផ្កា ជាលិកា កោសិកា និងផ្នែកដទៃទៀតនៃរុក្ខជាតិ។
- **អាជ្ញាបណ្ណ** សំដៅដល់កិច្ចសន្យាអាជ្ញាបណ្ណ ដែលម្ចាស់សិទ្ធិផ្តល់ការអនុញ្ញាតបន្តសម្រាប់ការប្រើប្រាស់សិទ្ធិពូជថ្មីនៃដំណាំ។

## ផ្នែកទី២

## ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

### ប្រការ៥._ ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី មានភារកិច្ចដូចខាងក្រោម៖

១- ទទួលបន្ទុកពិនិត្យសំណុំលិខិតស្នើសុំចុះបញ្ជីការពារពូជដំណាំ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

២- ពិនិត្យភាពថ្មីនៃពូជដំណាំ
៣- ផ្តល់វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ
៤- ផ្តល់ការការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ
៥- ផ្លាស់ប្តូរម្ចាស់សិទ្ធិ
៦- បញ្ចប់ មោឃភាព ឬលុបចោលពូជថ្មីនៃដំណាំ
៧- ចេញអាជ្ញាបណ្ណបញ្ជា
៨- កត់ត្រាអាជ្ញាបណ្ណ។

## ផ្នែកទី៣
## នីតិវិធីនៃការដាក់ពាក្យសុំ និងការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ

### ប្រការ៦._ ការដាក់ពាក្យស្នើសុំចុះបញ្ជីការពារពូជថ្មីនៃដំណាំ

អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីនៃដំណាំត្រូវៈ

១- មានសញ្ជាតិជាខ្មែរ ឬសញ្ជាតិបរទេស ប៉ុន្តែត្រូវមាននិវេសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

២- មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬរដ្ឋណាមួយដែលជាបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៧._ សំណុំលិខិតស្នើសុំចុះបញ្ជីការពារពូជថ្មីនៃដំណាំ

សំណុំលិខិតស្នើសុំចុះបញ្ជីការពារពូជថ្មីនៃដំណាំ រួមមានពាក្យសុំត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់ ដែលមានភ្ជាប់មកជាមួយនូវឯកសារ និងសំណាកពូជដំណាំតាមកាលបរិច្ឆេទ និងទីកន្លែងដែលកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី។

អ្នកដាក់ពាក្យសុំត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី តាមគំរូពាក្យស្នើសុំដែលបានកំណត់ក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ ហើយត្រូវបង់ថ្លៃសេវាតាមការកំណត់។

ពាក្យសុំត្រូវមានលក្ខណៈដូចខាងក្រោមៈ

១- ពាក្យសុំចុះបញ្ជីការពារពូជថ្មីនៃដំណាំ ត្រូវបំពេញតាមគំរូពាក្យសុំលេខ **១ព.ដ** ដូចមានភ្ជាប់ក្នុង **ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ។

២- ពាក្យសុំត្រូវបញ្ជាក់ ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងទីលំនៅរបស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ។

៣- ក្នុងករណីអ្នកដាក់ពាក្យសុំជាអ្នកបង្កាត់ពូជថ្មីនៃដំណាំ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនមែនជាអ្នកបង្កាត់ពូជថ្មីនៃដំណាំទេនោះ ពាក្យសុំត្រូវបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកបង្កាត់ពូជថ្មីនៃដំណាំម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះការការពារពូជថ្មីនៃដំណាំ។

៤- ប្រសិនបើអ្នកដាក់ពាក្យសុំ ត្រូវបានតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ និងថ្លែងបញ្ជាក់ផងដែរនូវឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ។

៥- ចំណងជើងនៃពូជដំណាំថ្មី ត្រូវតែខ្លី ហើយច្បាស់លាស់។

## ប្រការ៨._ ការបញ្ជាក់ឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន

ការបញ្ជាក់ឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោម៖

១- ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គលត្រូវបញ្ជាក់ដោយនាមត្រកូល នាមខ្លួនសញ្ជាតិ និងអាសយដ្ឋានរបស់បុគ្គលនោះ ឈ្មោះនីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញជាផ្លូវការរបស់នីតិបុគ្គលនោះ។

២- ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះជាជនជាតិ នីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះប្រទេសដែលនីតិបុគ្គលនោះបានបង្កើតនៅក្រោមច្បាប់នៃប្រទេសនោះ ព្រមទាំងការិយាល័យដែលបានចុះបញ្ជីរួចហើយរបស់នីតិបុគ្គលនោះ។

៣- ត្រង់ចំណុចអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់តាមវិធីណាមួយឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលបំពេញ និងបញ្ជូនឯកសារតាមប្រៃសណីយ៍បានឆាប់ទៅដល់អាសយដ្ឋានដែលបានបញ្ជាក់នោះ ហើយមានបញ្ជាក់លេខទូរស័ព្ទ លេខទូរសារ និងអាសយដ្ឋានអ៊ីម៉ែលផងដែរ ប្រសិនបើមានដើម្បីងាយស្រួលទំនាក់ទំនង។

៤- ត្រង់ចំណុចអាសយដ្ឋានត្រូវមាន បញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះមានអាសយដ្ឋានអចិន្ត្រៃយ៍។

៥- គ្រប់អ្នកដាក់ពាក្យសុំការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវអាសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់។

## ប្រការ៩._ ការប្តូរឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន

ការប្តូរឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោម៖

១- សំណើសុំដោយម្ចាស់ ឬដោយអ្នកសុំសិទ្ធិការពារពូជថ្មីនៃដំណាំដើម្បីប្តូរឈ្មោះ សញ្ជាតិអាសយដ្ឋានរបស់ខ្លួន ឬអាសយដ្ឋានសម្រាប់ទាក់ទងដែលបានកត់ត្រា ចំពោះការចុះបញ្ជីការពារពូជថ្មីនៃដំណាំ ឬនៅសំណុំលិខិតស្នើសុំខាងលើរបស់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២- មុននឹងអនុវត្តតាមសំណើសុំក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់ភស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការប្តូរឈ្មោះនោះ។

៣- ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្រប មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមការប្តូរឈ្មោះនោះ លើវិញ្ញាបនបត្រការពារពូជថ្មីនៃដំណាំ ឬក៏លើសំណុំលិខិតស្នើសុំ ហើយករណីដែលឈ្មោះ សញ្ជាតិ ឬអាសយដ្ឋានបានកត់ត្រារួចក្នុងបញ្ជី ក៏ត្រូវតែកត់ត្រាការប្តូរនោះឱ្យបានត្រឹមត្រូវ។

## ប្រការ១០._ ការចុះហត្ថលេខា

ការចុះហត្ថលេខា ត្រូវអនុវត្តដូចខាងក្រោម៖

១- ឯកសារដែលរៀបចំឡើងចុះហត្ថលេខាជួសមុខឱ្យ ក្នុងនាមក្រុមហ៊ុនសហសិទ្ធិមួយ ក្នុងនាមសហគមន៍ នៃបុគ្គលច្រើននាក់ឬក្នុងនាមអង្គភាពសាជីវកម្ម ត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ដោយមានលិខិតបញ្ជាក់ពីដៃគូនៃក្រុមហ៊ុនខាងលើ ដោយមានការផ្ទេរសិទ្ធិត្រឹមត្រូវទទួលស្គាល់

ថាបុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថាបុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ដើម្បីចុះហត្ថលេខា។

២- ក្នុងករណីយល់ថាចាំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឱ្យផ្តល់ភស្តុតាង ការអនុញ្ញាតឱ្យចុះហត្ថលេខា។

## ប្រការ១១._ ការទទួលពាក្យស្នើសុំសិទ្ធិការពារពូជថ្មីនៃដំណាំ

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវទទួលពាក្យស្នើសុំតាមនីតិវិធីដូចខាងក្រោម៖

១- ទទួលផ្ទាល់ពីអ្នកដាក់ពាក្យសុំ ឬតាមរយៈភ្នាក់ងារតំណាងឱ្យម្ចាស់សិទ្ធិ។

២- ទទួលពីការិយាល័យប្រៃសណីយ៍ក្នុងករណីកាលបរិច្ឆេទនៃការចុះបញ្ជីជិតដល់ថ្ងៃផុតសុពលភាពដែលការិយាល័យការពារពូជថ្មីនៃដំណាំ ត្រូវបញ្ចប់ការទទួលពាក្យ។

៣- នៅពេលដែលទទួលពាក្យស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវកំណត់សំគាល់លើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនិងលេខសំណុំលិខិតស្នើសុំដែលផ្សំជាអក្សរ "កជ" បន្ទាត់ទ្រេត "/" អក្សរ "ព.ដ" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់នៃឆ្នាំទទួលសំណុំលិខិតបន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំដែលបានទទួល។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួលនៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សម្គាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះ នៅកន្លែងសមស្របរបស់ពាក្យសុំពូជថ្មីនៃដំណាំ (គំរូពាក្យសុំលេខ ១ ព.ដ)។

## ប្រការ១២._ ចំនួនឯកសារ និងការតម្រូវរូបសាស្ត្រ

ចំនួនឯកសារ និងតម្រូវរូបសាស្ត្រត្រូវមានដូចខាងក្រោម៖

១- សំណុំលិខិតស្នើសុំ និងឯកសារភ្ជាប់ជាមួយត្រូវដាក់ជូនមន្ត្រីកាន់កាប់ញ្ជីចំនួន០២(ពីរ)ច្បាប់។ មន្ត្រីកាន់កាប់បញ្ជី អាចស្នើសុំឱ្យផ្តល់សំណុំលិខិតស្នើសុំឯកសារភ្ជាប់ជាមួយ មានចំនួនច្រើនច្បាប់បន្ថែមទៀតតាមការចំបាច់។

២- ឯកសារទាំងអស់នៃសំណុំលិខិតស្នើសុំត្រូវបង្ហាញផងដែរ អំពីការអនុញ្ញាតឱ្យផលិតសារជាថ្មីផ្ទាល់តែម្តងដោយរូបថត និងដំណើរការអេឡិចត្រូនិច ការបោះពុម្ព តាមរបៀបមីក្រូហ្វីល។

៣- អនុញ្ញាតឱ្យប្រើប្រាស់សន្លឹកក្រដាសតែម្ខាង សម្រាប់រៀបចំសំណុំលិខិតស្នើសុំ។

៤- ឯកសារទាំងអស់ នៃសំណុំលិខិតស្នើសុំ ត្រូវតែសរសេរលើក្រដាស ដែលងាយបត់បានមាំមិនងាយរហែក ពណ៌សរលោង មិនភ្លឺចាំង និងទុកបានយូរ។

៥- ទំហំនៃសន្លឹកក្រដាស ត្រូវយកទំហំ A4 (២១ស.មx២៩.៧ស.ម)។ មន្ត្រីកាន់កាប់បញ្ជីអាចយល់ព្រមទទួលសន្លឹកក្រដាស ដែលមានទំហំផ្សេងទៀតបានតាមការចាំបាច់។

៦- រឹមនៃសន្លឹកក្រដាសនីមួយៗ ត្រូវមានប្រវែងអប្បបរមាដូចខាងក្រោម៖

- រឹមខាងលើនៃទំព័រនីមួយៗ មានប្រវែង ២ ស.ម(ពីរសង់ទីម៉ែត្រ) លើកលែងតែទំព័រទីមួយ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាលយជកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- រឹមខាងលើទីមួយមានប្រវែង ៣ ស.ម(បីសង់ទីម៉ែត្រ)។
- រឹមជ្រុងម្ខាងដែលទុកសំរាប់កិបឬចងជាសៀវភៅមានប្រវែង២,៥ ស.ម (ពីរសង់ទីម៉ែត្រកន្លះ)។
- រឹមជ្រុងម្ខាងទៀតមានប្រវែង ២ ស.ម(ពីរសង់ទីម៉ែត្រ)។
- រឹមខាងក្រោមមានប្រវែង ២ ស.ម(ពីរសង់ទីម៉ែត្រ)។

៧- ការតម្រូវថែមទៀតលើសន្លឹកក្រដាសត្រូវអនុវត្តដូចខាងក្រោម៖

ក- គ្រប់សន្លឹកក្រដាសត្រូវដាក់លេខសន្លឹកទំព័រនៅផ្នែកខាងក្រោមចំកណ្តាលនៃទំព័រហើយលេខទំព័រនោះត្រូវដាក់តាមលេខលំដាប់ជាប់គ្នា។

ខ- ឯកសារទាំងអស់នៃសំណុំលិខិតស្នើសុំត្រូវរៀបដាក់តាមលំដាប់លំដោយលេខរៀងនៃសន្លឹកដូចតទៅ៖ ពាក្យសុំ សេចក្តីអធិប្បាយ សេចក្តីអះអាង ខ្លឹមសារសង្ខេបគំនូរបង្ហាញ ឬរូបថត។

គ- លំដាប់លំដោយលេខរៀងនៃសន្លឹករបស់សំណុំលិខិតស្នើសុំត្រូវបែងចែកជាលេខរៀងតៗគ្នាដោយឡែកពីគ្នាជា០៣(បី) ប្រភេទ។ លេខរៀងប្រភេទទី១ អនុវត្តចំពោះពាក្យសុំតែប៉ុណ្ណោះ ដែលចាប់ផ្តើមពីសន្លឹកទី១នៃពាក្យសុំ។ លេខរៀងប្រភេទទី២ ចាប់ផ្តើមពីទំព័រទី១នៃសេចក្តីអធិប្បាយហើយបន្តទៅសេចក្តីអះអាង និងរហូតដល់ទំព័រចុងក្រោយនៃខ្លឹមសារសង្ខេប។ លេខរៀងប្រភេទទី៣ អនុវត្តចំពោះសន្លឹកគំនូសបង្ហាញ តែប៉ុណ្ណោះដែលចាប់ផ្តើមពីសន្លឹកទី១ នៃគំនូសបង្ហាញ។

៨- អត្ថបទទាំងឡាយនៃសំណុំលិខិតស្នើសុំត្រូវតែវាយកុំព្យូទ័រ។ រីឯនិមិត្តសញ្ញាក្រាហ្វិច រូបមន្តគណិតវិទ្យា និងលក្ខណៈពិសេសផ្សេងទៀត អាចត្រូវបានអនុញ្ញាតឱ្យសរសេរដៃ ឬគូសបានប្រសិនបើចាំបាច់។

៩- គំនូសបង្ហាញត្រូវគូសបន្ទាត់ឱ្យបានល្អជាប់បានយូរ ពណ៌ខ្មៅ ដិតល្មម មានកម្រាស់ស្មើគ្នាច្បាស់ល្អ និងមិនគ្រើម ព្រមទាំងមិនជាប់ពណ៌ធម្មជាតិ។

## ប្រការ១៣._ ភាសានៃឯកសារ និងការបកប្រែ

ភាសានៃឯកសារ និងការបកប្រែ ត្រូវអនុវត្តដូចខាងក្រោម៖

១- សំណុំលិខិតស្នើសុំ និងឯកសារណាមួយដែលបានបង្កើតបានជាផ្នែកមួយនៃសំណុំលិខិតស្នើសុំ ឬឯកសារណាមួយដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ត្រូវអនុលោមតាមច្បាប់ និងប្រកាសនេះ និងបទបញ្ញាពាក់ព័ន្ធ ត្រូវធ្វើជាភាសាខ្មែរ។

២- សម្រាប់គោលបំណងនៃការស្រាវជ្រាវនិងការពិនិត្យ ក្នុងករណីសំណុំលិខិតស្នើសុំនិងឯកសារដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ត្រូវបានសរសេរជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី។

៣- សម្រាប់គោលបំណងនៃការវិនិច្ឆ័យ ការការពារ និងការអនុវត្តច្បាប់ ក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារមានចែងក្នុងចំណុច១ នៃប្រការនេះ ដែលបានសរសេរជាភាសាបរទេសក្រៅពីភាសា



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

ខ្មែរ ត្រូវបកប្រែជាភាសាខ្មែរ ហើយដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល៦(ប្រាំមួយ)ខែ ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី។

## ប្រការ១៤._ ការដកយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ

ការដកយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោម៖

១- អ្នកដាក់ពាក្យស្នើសុំ អាចដកយកទៅវិញបាននូវសំណុំលិខិតស្នើសុំ ដោយធ្វើពាក្យសុំជាលាយលក្ខណ៍ អក្សរដាក់ជូនមន្ត្រីកាន់កាប់បញ្ជី។

២- កម្រៃពាក់ព័ន្ធនឹងការដាក់សំណុំលិខិតស្នើសុំមិនត្រូវបានប្រគល់ជូនវិញទេ ប្រសិនបើសំណុំលិខិតស្នើសុំនោះត្រូវបានដកយកទៅវិញ។

## ប្រការ១៥._ ការពិនិត្យសំណុំលិខិតស្នើសុំ

ការពិនិត្យសំណុំលិខិតស្នើសុំសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ ត្រូវអនុវត្តដូចខាងក្រោម៖

១- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យសំណុំលិខិតស្នើសុំ តាមលក្ខខណ្ឌតម្រូវមាត្រា៣០នៃច្បាប់។

២- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវអញ្ជើញអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ឱ្យមកធ្វើការកែតម្រូវឱ្យបានរួចរាល់ក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ។ ប្រសិនបើអ្នកដាក់ពាក្យសុំមិនអនុវត្តតាមការអញ្ជើញឱ្យមកកែតម្រូវការខ្វះខាត ឬបើអ្នកដាក់ពាក្យសុំបានផ្តល់ការកែតម្រូវការខ្វះខាតនោះរួចហើយក៏ដោយក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរជាថ្មីម្តងទៀត ដោយបញ្ជាក់អំពីមូលហេតុនោះ និងឱ្យមានការកែតម្រូវឡើងវិញ ពុំនោះទេសំណុំលិខិតស្នើសុំនឹងត្រូវបដិសេធ។

៣- នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីយល់ព្រមចំពោះកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ហើយបញ្ជូនសំណុំលិខិតស្នើសុំមួយច្បាប់ព្រមទាំងសំណាកពូជសម្រាប់ធ្វើតេស្តទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើតេស្តវាយតម្លៃលក្ខណៈបច្ចេកទេស ក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីថ្ងៃបញ្ចប់ការត្រួតពិនិត្យសំណុំលិខិតស្នើសុំ។

## ប្រការ១៦._ ការត្រួតពិនិត្យទៅលើការដាក់ឈ្មោះពូជថ្មីនៃដំណាំ

១- មន្ត្រីកាន់កាប់បញ្ជី ត្រូវពិនិត្យភាពត្រឹមត្រូវនៃការស្នើសុំដាក់ឈ្មោះពូជថ្មីនៃដំណាំនេះ ដើម្បីប្រៀបធៀបទៅនឹងប្រភេទពូជដំណាំដទៃទៀតដែលដូចគ្នា ឬស្រដៀងគ្នាទៅនឹងពូជដំណាំដែលមានរួចហើយ ក្នុងប្រភេទពូជដំណាំតែមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅរដ្ឋភាគីហត្ថលេខីណាមួយដែលបានចុះកិច្ចព្រមព្រៀងជាមួយកម្ពុជា ក្នុងកិច្ចការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

២- ក្នុងករណីការដាក់ឈ្មោះពូជថ្មីនៃដំណាំសម្រាប់ចុះបញ្ជីការពារសិទ្ធិមិនបានត្រឹមត្រូវ មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើលិខិតទៅអ្នកដាក់ពាក្យសុំ តម្រូវឱ្យមានការផ្លាស់ប្តូរឈ្មោះពូជថ្មីនៃដំណាំដោយយោងទៅតាមបទបញ្ញានៃប្រកាសនេះ។ ក្នុងរយៈពេល៣ (បី)ខែ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងពីមន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យសុំត្រូវស្នើសុំដាក់ឈ្មោះពូជដំណាំសាជាថ្មីដោយអនុលោមតាមបទបញ្ញានៃប្រកាសនេះ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំខកខានមិនបានស្នើសុំដាក់ឈ្មោះពូជដំណាំសារជាថ្មី ឱ្យបានសមស្របតាមពេលវេលាកំណត់ទេនោះ មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធពាក្យស្នើសុំ។

៣- ប្រសិនអ្នកដាក់ពាក្យស្នើសុំ មានបំណងផ្លាស់ប្តូរឈ្មោះពូជថ្មីនៃដំណាំអាចធ្វើទៅបានមុនការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ។ ការស្នើសុំផ្លាស់ប្តូរឈ្មោះពូជថ្មីនៃដំណាំ ត្រូវធ្វើឡើងដំណាលគ្នានៃការស្នើសុំឈ្មោះថ្មីនៃពូជដំណាំសម្រាប់ចុះបញ្ជីការពារពូជថ្មីនៃដំណាំ និងត្រូវបង់កម្រៃតាមការកំណត់។

៤- មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានទាំងអស់លើការដាក់ឈ្មោះពូជថ្មីនៃដំណាំ។ ការដាក់ឈ្មោះពូជថ្មីនៃដំណាំមានការទទួលស្គាល់ជាផ្លូវការ និងផ្តល់ជូននៅពេលទទួលបានសិទ្ធិការពារពូជថ្មីនៃដំណាំ។

## ប្រការ១៧._ ការវាយតម្លៃរបាយការណ៍លទ្ធផលនៃការពិនិត្យលក្ខណៈបច្ចេកទេស

ការវាយតម្លៃរបាយការណ៍លទ្ធផលនៃការពិនិត្យលក្ខណៈបច្ចេកទេស ត្រូវអនុវត្តដូចខាងក្រោម៖

១- អនុលោមមាត្រា៣០នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យរបាយការណ៍ស្រាវជ្រាវ និងរបាយ-ការណ៍ពិនិត្យលក្ខណៈបច្ចេកទេស និងត្រូវផ្សព្វផ្សាយរបាយការណ៍លទ្ធផលនៃការពិនិត្យលក្ខណៈបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងពីស្ថាប័នជំនាញផ្សេងទៀត។

២- បុគ្គលដែលពាក់ព័ន្ធអាចដាក់ពាក្យប្តឹងជំទាស់ចំពោះការការពារពូជថ្មីនៃដំណាំ ទៅមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៣(បី) ខែបន្ទាប់ពីការផ្សព្វផ្សាយរបាយការណ៍លទ្ធផលនៃការពិនិត្យលក្ខណៈបច្ចេកទេស ក្នុងព្រឹត្តិបត្រផ្លូវការ។

៣- ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា៦ និងមាត្រា២៦ នៃច្បាប់មិនត្រូវបានបំពេញទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរអំពីការពិនិត្យលទ្ធផលស្រាវជ្រាវ និងពិនិត្យលក្ខណៈបច្ចេកទេសធ្វើតេស្ត ព្រមទាំងអញ្ជើញឱ្យមកពិនិត្យលទ្ធផលធ្វើតេស្ត និងកែតម្រូវពាក្យសុំក្នុងរយៈពេល ៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

៤- ក្នុងករណីអ្នកដាក់ពាក្យសុំមិនអនុវត្តតាមការអញ្ជើញខាងលើនេះទេ ឬករណីដែលបានពិនិត្យលទ្ធផលធ្វើតេស្ត និងកែតម្រូវពាក្យសុំរួចហើយក៏ដោយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌទាំងឡាយដែលបានចែងក្នុងមាត្រា៦ និងមាត្រា២៦នៃច្បាប់ មិនបានបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

៥- មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ជាលាយលក្ខណ៍អក្សរអំពីការសម្រេចផ្តល់ ឬបដិសេធការផ្តល់សិទ្ធិការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ ដោយត្រូវភ្ជាប់ជាមួយនូវរបាយការណ៍ស្រាវជ្រាវនិងរបាយការណ៍បច្ចេកទេស ដែលជាមូលដ្ឋាននៃការសម្រេច។

៦- ក្នុងករណីមិនមានការប្តឹងជំទាស់ក្នុងរយៈពេល៣ (បី)ខែ បន្ទាប់ពីការផ្សព្វផ្សាយ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការនីតិវិធីនៃការផ្តល់ការការពារពូជថ្មីនៃដំណាំ បើពិនិត្យឃើញថាលក្ខខណ្ឌទាំងឡាយត្រូវបានបំពេញ ឬបដិសេធក្នុងករណីលក្ខខណ្ឌទាំងឡាយមិនត្រូវបានបំពេញ។

## ប្រការ១៨.- ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ និងការបោះពុម្ពផ្សាយ

ការផ្តល់សិទ្ធិ និងការបោះពុម្ពផ្សាយសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវអនុវត្តដូចខាងក្រោម៖

១- មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់វិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ បន្ទាប់ពីអ្នកដាក់ពាក្យសុំបានបង់កម្រៃសេវាផ្តល់សិទ្ធិការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំ ដូចមានចែងក្នុងមាត្រា៣៧ នៃច្បាប់។

២- មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ ហើយត្រូវបោះពុម្ពផ្សាយជាសាធារណៈក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើវិញ្ញាបនបត្រ។

៣- បុគ្គលដែលពាក់ព័ន្ធអាចធ្វើបណ្តឹងឧបាស្រ័យ (ប្តឹងជំទាស់) ចំពោះសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីក្នុងការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

៤- ការបោះពុម្ពផ្សាយ នូវសេចក្តីបញ្ជាក់អំពីការផ្តល់វិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំត្រូវមាន៖

ក- លេខវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ

ខ- ឈ្មោះ និងអាសយដ្ឋាន របស់ម្ចាស់សិទ្ធិការពារពូជថ្មីនៃដំណាំ

គ- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកបង្កាត់ពូជ លើកលែងតែអ្នកបង្កាត់ពូជបានសុំឱ្យដាក់ឈ្មោះរបស់ខ្លួននៅក្នុងវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ។

ឃ- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារ ប្រសិនបើមាន

ង- កាលបរិច្ឆេទសុំចុះបញ្ជី

ច- សេចក្តីប្រកាសអំពីសិទ្ធិអាទិភាព លេខសំណុំលិខិត កាលបរិច្ឆេទអាទិភាព និងឈ្មោះរបស់ប្រទេសទាំងឡាយ ដែលសំណុំលិខិតស្នើសុំបានដាក់មុនគេ ប្រសិនបើកាលបរិច្ឆេទអាទិភាពត្រូវបានអះអាង ហើយការអះអាងត្រូវបានយល់ព្រមទទួលស្គាល់។

ឆ- កាលបរិច្ឆេទផ្តល់វិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ

ជ- ឈ្មោះពូជដំណាំ

ឈ- ខ្លឹមសារសង្ខេប

ញ- រូបថតដែលផ្តល់ការពន្យល់ច្បាស់លាស់ជាងគេ ប្រសិនបើមាន។

៥- ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា៣០ នៃច្បាប់ និងប្រកាសនេះត្រូវបានបំពេញហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់សិទ្ធិការពារសិទ្ធិអ្នកបង្កាត់ពូជថ្មីនៃដំណាំជូនអ្នកដាក់ពាក្យសុំ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

## ប្រការ១៩.- ភ្នាក់ងារ

ភ្នាក់ងារត្រូវអនុវត្តដូចខាងក្រោម៖

១- អនុលោមតាមមាត្រា ៣៨ នៃច្បាប់ ការចាត់តាំងភ្នាក់ងារតំណាងត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើអ្នកដាក់ពាក្យសុំលើសពីមួយនាក់។ អាសយដ្ឋានភ្នាក់ងារតំណាង ត្រូវចាត់ទុកជាអាសយដ្ឋានទាក់ទងដើម្បីបញ្ជូនដំណឹងបុគ្គលម្នាក់ឬច្រើននាក់ដែលបាន ចាត់តាំងភ្នាក់ងារនោះសម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធទៅនឹងច្បាប់ និងប្រកាសនេះ។

២- លិខិតប្រគល់សិទ្ធិឱ្យភ្នាក់ងារដូចមានចែង ក្នុងចំណុច១នៃប្រការនេះ ត្រូវដាក់ភ្ជាប់ជាមួយសំណុំលិខិតស្នើសុំ ឬដែលអាចប្រគល់ក្នុងរយៈពេល២ (ពីរ) ខែគិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំនោះ។

៣- ប្រសិនបើការចាត់ភ្នាក់ងារមិនត្រូវបានអនុវត្ត ដូចមានចែងក្នុងចំណុច២ នៃប្រការនេះទេ ហើយមិនស្របតាមមាត្រា ៣៨ នៃច្បាប់ ចំណាត់ការជានីតិវិធីណាមួយ ដែលធ្វើដោយភ្នាក់ងារក្រៅពីការដាក់សំណុំ លិខិតស្នើសុំចុះបញ្ជី ត្រូវចាត់ថាមិនបានធ្វើឡើយ ។

៤- ការតម្រូវនានា ពាក់ព័ន្ធភ្នាក់ងារតំណាងរបស់អ្នកដាក់ពាក្យសុំ ដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ត្រូវចែងដោយបទប្បញ្ញត្តិដោយឡែក ដោយកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ។

## ប្រការ២០.- ថ្ងៃលើកលែង

កាលណាថ្ងៃចុងក្រោយនៃអំឡុងពេលសម្រាប់អនុវត្តកិច្ចការអ្វីមួយឬចំណាត់ការអ្វីមួយ ត្រូវនឹងថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលច្បាប់ ឬបទដ្ឋានគតិយុត្តិបានកំណត់ ហើយនាយកដ្ឋានទទួលបន្ទុកមិនបម្រើសាធារណៈជនទេ ដូច្នេះកិច្ចការឬចំណាត់ការនោះអាចអនុវត្តបាននៅថ្ងៃធ្វើការដំបូងបន្ទាប់ពីថ្ងៃឈប់នោះ។

## ប្រការ២១.- ការដកស្រង់ព័ត៌មានពីបញ្ជី និងការកែតម្រូវកំហុស

ការដកស្រង់ព័ត៌មាន និងការកែតម្រូវកំហុសត្រូវអនុវត្តដូចខាងក្រោម៖

១- ការស្នើសុំច្បាប់ចម្លង ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើមនៃការដកស្រង់ព័ត៌មានពីបញ្ជី ឬការស្នើសុំថតចម្លងឯកសារផ្សេងៗ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី។

២- ការកែតម្រូវកំហុសអាចត្រូវធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយបំពេញលក្ខខណ្ឌទាំងឡាយដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសមស្រប ឬតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី។ ការកែតម្រូវទាំងឡាយដែលបានធ្វើឡើង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលពាក់ព័ន្ធទាំងឡាយ ហើយក្នុងករណីចាំបាច់ត្រូវបោះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

## ប្រការ២២._ បណ្ដឹងជំទាស់ និងបណ្ដឹងឧបាស្រ័យ

បុគ្គលដែលពាក់ព័ន្ធអាចដាក់ពាក្យប្ដឹងជំទាស់ ចំពោះការការពារពូជថ្មីនៃដំណាំទៅមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ៣ (បី)ខែ បន្ទាប់ពីលទ្ធផលនៃការពិនិត្យត្រូវបានបោះពុម្ពផ្សាយក្នុងព្រឹត្តបត្រផ្លូវការ។

បុគ្គលណាដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការផ្ដល់សិទ្ធិការពារពូជថ្មីនៃដំណាំ អាចធ្វើបណ្ដឹងឧបាស្រ័យចំពោះការសម្រេចនោះទៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

## ប្រការ២៣._ ការបង់កម្រៃសេវារដ្ឋបាលនៃការចុះបញ្ជីការពារ និងកម្រៃរក្សាសុពលភាពប្រចាំឆ្នាំ

ការបង់កម្រៃសេវារដ្ឋបាលពាក់ព័ន្ធនឹងការចុះបញ្ជីការពារ និងបង់កម្រៃរក្សាសុពលភាពប្រចាំឆ្នាំនៃសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវអនុវត្តដូចខាងក្រោម៖

១- កម្រៃសេវារដ្ឋបាលពាក់ព័ន្ធក្នុងការចុះបញ្ជីការពារ និងកម្រៃរក្សាសុពលភាពប្រចាំឆ្នាំ នៃសិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវកំណត់ដោយប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

២- ការបង់កម្រៃប្រចាំឆ្នាំ ត្រូវអនុវត្តដូចខាងក្រោម៖

ក- មន្ត្រីកាន់កាប់បញ្ជីត្រូវប្រគល់ ឬផ្ញើលិខិតជូនដំណឹងអំពីការបង់កម្រៃប្រចាំឆ្នាំ ជូនអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ ។

ខ- មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រា និងបោះផ្សាយសេចក្ដីជូនដំណឹង អំពីការអស់សុពលភាពវិញ្ញាបនបត្រសិទ្ធិការពារពូជថ្មីនៃដំណាំ។

## ប្រការ២៤._ កិច្ចសហការ

នាយកដ្ឋានសិទ្ធិឧស្សាហកម្ម ត្រូវសហការជាមួយស្ថាប័ន អង្គភាព និងអង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីជំរុញការការពារសិទ្ធិឧស្សាហកម្ម និងអភិវឌ្ឍប្រព័ន្ធការពារពូជថ្មីនៃដំណាំ។

# ផ្នែកទី៤
# ការផ្លាស់ប្ដូរសិទ្ធិការពារពូជថ្មីនៃដំណាំ

## ប្រការ២៥._ ការប្ដូរម្ចាស់សិទ្ធិ និងអាជ្ញាបណ្ណ

ការប្ដូរម្ចាស់សិទ្ធិ និងអាជ្ញាបណ្ណ ត្រូវអនុវត្តដូចខាងក្រោម៖

១- អនុលោមតាមមាត្រា ៣៤ នៃច្បាប់ សំណើសុំការកត់ត្រាការប្ដូរម្ចាស់សិទ្ធិនៃសំណុំលិខិត ស្នើសុំចុះបញ្ជីការពារពូជថ្មីនៃដំណាំ ត្រូវបំពេញតាមគំរូពាក្យសុំតាមការកំណត់ ហើយម្ចាស់សិទ្ធិត្រូវបង់កម្រៃតាមការកំណត់។

២- អ្នកដាក់ពាក្យសុំការពារសិទ្ធិ ឬម្ចាស់សិទ្ធិពូជថ្មីនៃដំណាំអាចប្រគល់ទៅឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀតនូវអាជ្ញាបណ្ណផ្ដាច់មុខ អាជ្ញាបណ្ណមិនផ្ដាច់មុខទាក់ទងនឹងសិទ្ធិទាំងអស់ ឬសិទ្ធិណាមួយផ្ដល់ជូនតាមច្បាប់នេះ។ អ្នកដាក់ពាក្យសុំការពារសិទ្ធិ ឬម្ចាស់សិទ្ធិពូជថ្មីនៃដំណាំអាចស្នើសុំការកត់ត្រាការផ្ដល់អាជ្ញាបណ្ណផ្ដាច់មុខ ឬមិនផ្ដាច់មុខ ទៅមន្ត្រីកាន់កាប់បញ្ជី និងបង់


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

កម្រៃតាមការកំណត់។ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាការផ្តល់អាជ្ញាបណ្ណផ្តាច់មុខឬមិនផ្តាច់មុខតាមការស្នើសុំ។

៣- ការផ្សព្វផ្សាយស្តីពីការប្តូរម្ចាស់សិទ្ធិត្រូវបញ្ជាក់អំពី៖

ក- ឈ្មោះពូជដំណាំដែលបានដាក់ការពារ

ខ- កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាព ប្រសិនបើមាន និងកាលបរិច្ឆេទនៃការចុះបញ្ជី ឬកាលបរិច្ឆេទនៃការផ្តល់។

គ- ម្ចាស់សិទ្ធិ និងម្ចាស់សិទ្ធិថ្មី

ឃ- លក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ

## ផ្នែកទី៥
## អាជ្ញាបណ្ណបញ្ជា

### ប្រការ២៦.- អាជ្ញាបណ្ណបញ្ជា

អនុលោមតាមមាត្រា៣៥នៃច្បាប់ រូបវន្តបុគ្គល ឬនីតិបុគ្គល អាចដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យផ្តល់អាជ្ញាបណ្ណបញ្ជាក្នុងការប្រើប្រាស់ពូជថ្មីនៃដំណាំ ដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ ដើម្បីការពារផលប្រយោជន៍សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកទទួលអាជ្ញាបណ្ណបញ្ជា ត្រូវបង់ប្រាក់សំណងសមស្របទៅឱ្យម្ចាស់កម្មសិទ្ធិពូជថ្មីនៃដំណាំ។

បែបបទ និងនីតិវិធី នៃអាជ្ញាបណ្ណបញ្ជានឹងត្រូវកំណត់ដោយប្រកាសដោយឡែក។

## ផ្នែកទី៦
## ការបញ្ចប់ មោឃភាព និងការលុបចោល

### ប្រការ២៧.- ការបញ្ចប់

សិទ្ធិការពារពូជថ្មីនៃដំណាំត្រូវបានបញ្ចប់ក្នុងករណីដែលម្ចាស់សិទ្ធិបោះបង់ចោលសិទ្ធិ ដោយធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនមន្ត្រីកាន់កាប់បញ្ជី។ កាលបរិច្ឆេទនៃការបញ្ចប់ ត្រូវបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬបើគ្មានការកំណត់កាលបរិច្ឆេទច្បាស់លាស់នៅក្នុងលិខិតជូនដំណឹងនោះទេ ត្រូវយកកាលបរិច្ឆេទដែលមន្ត្រីកាន់កាប់បញ្ជីទទួលបានលិខិតជូនដំណឹងនោះ។ មន្ត្រីកាន់កាប់បញ្ជីត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការអំពីការបោះបង់ចោលសិទ្ធិនេះ។

### ប្រការ២៨.- មោឃភាព

សិទ្ធិពូជថ្មីនៃដំណាំត្រូវប្រកាសជាមោឃភាពក្នុងករណីដែល៖

១- លក្ខខណ្ឌភាពថ្មី ឬភាពខុសប្លែកមិនត្រូវបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ




ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

២- លក្ខខណ្ឌឯកសណ្ឋានភាព ឬស្ថិរភាពមិនត្រូវបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ
៣- សិទ្ធិជាម្ចាស់ពូជថ្មីនៃដំណាំត្រូវបានផ្តល់ទៅឱ្យបុគ្គលដែលគ្មានសិទ្ធិទទួល។

ក្នុងករណីទទួលបានពាក្យសុំមោឃភាពសិទ្ធិពូជថ្មីនៃដំណាំ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យពាក្យសុំ និងជូនដំណឹងទៅម្ចាស់សិទ្ធិអំពីការសុំមោឃភាព ដើម្បីឱ្យម្ចាស់សិទ្ធិធ្វើការតវ៉ាក្នុងរយៈពេល៦ (ប្រាំមួយ)ខែ និងប្រសិនបើពាក់ព័ន្ធលក្ខណៈបច្ចេកទេសធ្វើតេស្ត ត្រូវជូនដំណឹងទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យសាឡើងវិញនូវលទ្ធផលស្រាវជ្រាវនិងពិនិត្យលក្ខណៈបច្ចេកទេសធ្វើតេស្ត។

បន្ទាប់ពីបានទទួលលទ្ធផលស្រាវជ្រាវនិងពិនិត្យលក្ខណៈបច្ចេកទេសធ្វើតេស្តសាឡើងវិញ និងពិនិត្យហេតុផលរបស់ម្ចាស់សិទ្ធិ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថាតើការសុំមោឃភាពនេះសមស្របដែរឬទេ ក្នុងករណីពិនិត្យឃើញថាការសុំជាមោឃភាពនេះត្រឹមត្រូវ មន្ត្រីកាន់កាប់បញ្ជីត្រូវចេញសេចក្តីសម្រេចជាមោឃភាពបឋម ហើយជូនដំណឹងដល់ម្ចាស់សិទ្ធិអំពីសេចក្តីសម្រេចនេះ។ ផ្ទុយទៅវិញ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា ការសុំជាមោឃភាពសិទ្ធិពូជថ្មីនៃដំណាំមិនត្រឹមត្រូវទេ មន្ត្រីកាន់កាប់បញ្ជីត្រូវចេញសម្រេចបដិសេធបឋមអំពីការបដិសេធនូវការស្នើសុំមោឃភាព ហើយជូនដំណឹងអំពីការបដិសេធទៅអ្នកដាក់ពាក្យសុំ និងជូនដំណឹងទៅម្ចាស់សិទ្ធិអំពីសេចក្តីសម្រេចនេះ។ ភាគីណាមួយដែលមិនពេញចិត្តនឹងសេចក្តីសម្រេចនេះ អាចធ្វើការតវ៉ាមកមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល៦ (ប្រាំមួយ)ខែ ដើម្បីធ្វើការពិនិត្យឡើងវិញ ក្នុងករណីការតវ៉ាក្រោយរយៈពេល៦ (ប្រាំមួយ)ខែ មិនត្រូវបានយកមកពិនិត្យឡើយ។ សេចក្តីសម្រេចចុងក្រោយរបស់មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងទៅភាគីទាំងពីរ និងត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ។

## ប្រការ២៩.- ការលុបចោល

សិទ្ធិពូជថ្មីនៃដំណាំត្រូវលុបចោលក្នុងករណីដែល៖

១- លក្ខខណ្ឌឯកសណ្ឋានភាព ឬស្ថិរភាពមិនត្រូវបានបំពេញដូចកាលពីពេលផ្តល់សិទ្ធិ
២- ម្ចាស់សិទ្ធិពូជថ្មីនៃដំណាំមិនត្រូវបានអនុវត្តតាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជីដោយ៖
- មិនផ្តល់ព័ត៌មាន ឯកសារ ឬពូជដំណាំដែលចាំបាច់សម្រាប់ការផ្ទៀងផ្ទាត់
- ខកខានមិនបានបង់កម្រៃដើម្បីរក្សាសិទ្ធិឱ្យនៅជាធរមាន ឬ
- មិនបានផ្តល់ឈ្មោះថ្មីសមស្រប បន្ទាប់ពីពូជដំណាំដែលទទួលបានសិទ្ធិការពារនោះត្រូវបានលុប។

អនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ និង២នៃប្រការនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវចេញសេចក្តីសម្រេចលុបចោលបឋម ហើយជូនដំណឹងដល់ម្ចាស់សិទ្ធិអំពីសេចក្តីសម្រេចនេះ។ ក្នុងករណីម្ចាស់សិទ្ធិមិនពេញចិត្តនឹងសេចក្តីសម្រេចលុបចោលបឋមនេះ ម្ចាស់សិទ្ធិអាចធ្វើការតវ៉ាមកមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ដើម្បីធ្វើការពិនិត្យឡើងវិញ។ សេចក្តីសម្រេចចុងក្រោយរបស់មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងម្ចាស់សិទ្ធិ និងត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

# ផ្នែកទី ៦

# អវសានប្បញ្ញត្តិ

## ប្រការ៣០.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

## ប្រការ៣១.- សមត្ថកិច្ចអនុវត្ត

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរូបវន្តបុគ្គលឬនីតិបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ។

## ប្រការ៣២.- ប្រសិទ្ធភាព

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

«ដើម្បីជូនជ្រាប»

- ដូចប្រការ៣១ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com